អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# ការតែងតាំងចៅក្រមថ្មីនៅ អ.វ.ត.ក

បន្ទាប់ពីមានការចាត់តាំងពីឯកឧត្តម បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ទ្រង់បានតែងតាំងចៅក្រម BAIK Kang Jin (ជនជាតិកូរ៉េខាងត្បូង) ជាចៅក្រមអន្តរជាតិថ្មីនៅអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ លោកជំនួសចៅក្រម រ៉ូវ៉ាន់ ដោននីង (ជនជាតិអូស្ត្រាលី) ដែលបានលាលែងតំណែងកាលពីដើមឆ្នាំនេះ។

កាលពីពេលថ្មីៗនេះ ចៅក្រម BAIK បានបំពេញការងារជាចៅក្រមនៅតុលាការកំពូលទីក្រុងសេអ៊ូល (Seoul High Court)។ តាំងពីឆ្នាំ ២០១៣មក លោកបានបំពេញការងារជាតំណាងពិសេស (special commissioner) នៃក្រុមប្រឹក្សាទទួលខុសត្រូវផ្នែកកម្មសិទ្ធិបញ្ញា (Presidential Council on Intellectual Property) និងជាសមាជិកមិនអចិន្ត្រៃយ៍ (non-standing commissioner) នៃគណៈកម្មការការពារព័ត៌មានផ្ទៃក្នុងរដ្ឋាភិបាលកូរ៉េ។ ចៅក្រម BAIK ត្រូវបានតែងតាំងជាចៅក្រមលើកដំបូងនៅឆ្នាំ ១៩៩៤ហើយគាត់បានចូលរួមក្នុងការជំនុំជម្រះក្តីលើសំណុំរឿងឧក្រិដ្ឋកម្មមួយចំនួននៅក្នុងតុលាការថ្នាក់ក្រោមបីផ្សេងគ្នាក្នុងប្រទេសកំណើតរបស់លោក។ ចៅក្រម BAIK បានទទួលសញ្ញាបរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យជាតិសេអ៊ូលនៅឆ្នាំ ១៩៩២។ លោកបានទទួលសញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យច្បាប់ George Washington នៅឆ្នាំ ២០០៤ និងបានបំពេញកម្មវិធី SJD ជាមួយសាកលវិទ្យាល័យច្បាប់ជាតិសេអ៊ូលនៅឆ្នាំ ២០១០។

ដោយឡែក លោកសាស្ត្រាចារ្យ Michael Bohlander (ជនជាតិអាល្លឺម៉ង់) ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងថ្មី ជំនួសចៅក្រម Olivier Beauvallet (ជនជាតិបារាំង) ដែលត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះកាលពីពេលកន្លងមក ក្នុងឆ្នាំនេះ។ បច្ចុប្បន្ន សាស្ត្រាចារ្យ Bohlander ជាប្រធានផ្នែកនីតិព្រហ្មទណ្ឌអន្តរជាតិ និងប្រៀបធៀប នៅសាលាច្បាប់ Durham ដែលគាត់បានបំពេញការងារជាសាស្ត្រាចារ្យ តាំងពីឆ្នាំ ២០០៤ មក។ ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០៤ សាស្ត្រាចារ្យ Bohlander បានបំពេញការងារជាចៅក្រមសាលាដំបូង និងសាលាឧទ្ធរណ៍ជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី នៅតុលាការនៃរដ្ឋសេរី Thuringia ប្រទេសអាល្លឺម៉ង់ខាងកើត (East German Free State of Thuringia)

នៅក្នុងដំណាក់កាលអន្តរកាល បន្ទាប់ពីការរួបរួមរបស់ប្រទេសអាល្លឺម៉ង់នៅឆ្នាំ ១៩៩០។ ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០១ គាត់បានបំពេញការងារជាមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ សាស្ត្រាចារ្យ Bohlander បានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកច្បាប់ និងសញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យ Saarland។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖


**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិកៈ olsenl@un.org